## ៥.៤ ការដាំដើមឈើនៅលើដីចំការឯកជន

ការដាំដើមឈើនៅលើដីចំការឯកជនកំពុងពេញនិយមយ៉ាងខ្លាំងបន្ទាប់ពីការទទួលស្គាល់ថាទៅថ្ងៃអនាគត ផលិតផលឈើនឹងមានប្រភពមកពីក្រៅតំបន់ព្រៃ។ ទោះបីជាមានលក្ខណៈតូចតាច ការដាំដើមឈើនៅលើដីចំការឯកជនមានលក្ខណៈនិរន្តរភាព ការចំណាយមានប្រសិទ្ធភាព និងជំរុញឱ្យមានសហគ្រិនភាពនៅមូលដ្ឋាន។ ក៏ប៉ុន្តែមានឧបសគ្គមួយចនួនត្រូវបានគេប្រមើលមើលឃើញ ដូចជា ទន្ទឹមនឹងការបង្កើនផ្ទៃដីដាំដុះ នោះគេជួបប្រទះនូវបញ្ហាថវិកា (គ្មានប្រាក់កម្ចី) និងភាពនៅឆ្ងាយពីទីផ្សារ។ បញ្ហាទាំងអស់នោះអាចត្រូវដោះស្រាយដោយការជួយអន្តរាគមន៍តាមរយៈនយោបាយគាំទ្ររបស់រដ្ឋាភិបាល ដូចជាការលើកទឹកចិត្ត ការផ្តល់នូវប្រាក់ឧបត្ថម្ភធន និងសេវាកម្មគាំទ្រ ផ្សេងៗទៀត ព្រមទាំងការបង្កើតភាពជាដៃគូរវាងអ្នកកាន់កាប់ដីតូចតាច រដ្ឋាភិបាល និង ផ្នែកឯកជន (Pasicolan, 2003)។

នៅកម្ពុជា ជំរើសនេះមានលក្ខណៈក្មេងខ្ចីនៅឡើយ ហើយវិធីសាស្ត្រនេះគេគួររាប់បញ្ចូលផងដែរនូវៈ

- ការដាំឈើជាលក្ខណៈពាណិជ្ជកម្មជាទ្រង់ទ្រាយតូច សំរាប់ទីផ្សារក្នុងស្រុក
- សហគមន៍/អ្នកម៉ៅការតូចតាច ដើម្បីផលិតនូវផលិតផលអ្វីមួយ

# ៦. ដំណើរការក្នុងការកំណត់តំបន់អាទិភាពសំរាប់ដាំឈើ

(សូមមើលគំនូសតាង នៅក្នុងឧបសម្ព័ន្ធទី ១)

ដំណើរការក្នុងការកំណត់តំបន់អាទិភាពសំរាប់ដាំឈើត្រូវបានបំបែកជាជំហាន២ ដើម្បីឱ្យតំបន់ដែលមិនសមស្របសំរាប់ការងារដាំឈើត្រូវបានជំរុះចោលឱ្យបានឆាប់មុនពេលដែលធនធានជាច្រើនត្រូវបានចំណាយសំរាប់ការងារចុះសិក្សាទីតាំង។ នៅពេលដែលទីតាំងណាមួយត្រូវបានសិក្សាតាមរយៈជំហានជាបន្តបន្ទាប់ នោះគេនឹងទទួលបានពត៌មានកាន់តែច្រើនឡើង ដូច្នេះទាមទារឱ្យមានការចាប់អារម្មណ៏អំពីតំរូវការនៃថវិកា និង ធនធានមនុស្ស។

ជំហានទីមួយគឺជាការសិក្សានៅនឹងការិយាល័យ ដោយប្រើប្រាស់ផែនទីដែលមាននៅក្នុងឧបសម្ព័ន្ធទី ៥។ ជំហានជាបន្តបន្ទាប់ទៀតគឺជាការសិក្សានៅនឹងទីវាលជាក់ស្តែង។

## ៦.១ ជំហានទី១_កំណត់តំបន់ដែលអាចមានលទ្ធភាពដាំដើមឈើ

**គោលដៅៈ** កំណត់ទីតាំងដែលសមស្របសំរាប់បំពេញកម្មវត្ថុនានានៃការដាំឈើ ដោយប្រើប្រាស់ផែនទីនានា លក្ខណៈវិនិច្ឆ័យ និង សន្ទស្សន៍។

៦.១.១ កំណត់ឱ្យបានច្បាស់លាស់នូវកម្មវត្ថុនៃការដាំឈើដែលចិតនៅជុំវិញកម្មវត្ថុសំខាន់ៗបីដូចខាងក្រោមៈ

- o កាត់បន្ថយភាពក្រីក្រ
- o ការពារបរិស្ថាន
- o អភិវឌ្ឍន៍សេដ្ឋកិច្ច

នៅក្នុងការអនុវត្តន៍ជាក់ស្តែងកម្មវត្ថុទាំងបីនេះមានលក្ខណៈលាយឡំគ្នាសំរាប់កម្មវិធីដាំឈើមួយចំនួនធំ ដូច្នេះគោលការណ៏ណែនាំនេះរៀបចំឡើងសំរាប់ការអនុវត្តជាទូទៅនៃគ្រប់ជំរើសនានា ដោយឡែកឯកសារលំអិតទាក់ទងនឹងកម្មវត្ថុនិមួយៗអាចរកបាននៅក្នុងឯកសារគាំទ្រនានា។

៦.១.២ ពិចារណានិងវាយតម្លៃជំរើសក្នុងការគ្រប់គ្រងមួយចំនួនដើម្បីជ្រើសរើសយកជំរើសមួយណាដែលអាចបំពេញកម្មវត្ថុនៃការដាំឈើ។ តារាងទីមួយផ្តល់ឧទាហរណ៏មួយចំនួននិងបង្ហាញពីតំរូវការឱ្យមានការប្រកាន់យកនូវជំរើសចំរុះនៅក្នុងករណីខ្លះដូចជានៅក្នុងករណីដាំឈើជាលក្ខណៈឧស្សាហកម្មដែល នៅទីនោះគេត្រូវលៃទុកតំបន់ (ផ្នែកខ្លះ) នៃផ្ទៃដីសំរាប់ឱ្យសហគមន៏ប្រើប្រាស់ ឬក៏សំរាប់ការពារទីជំរាល។ សេចក្តីលំអិតបន្ថែមនិងបទពិសោធន៏នានា នៅក្នុងការប្រកាន់យកនូវជំរើសទាំងនេះមានបង្ហាញក្នុងទំព័របន្ថែមទី ១។

**តារាងទី ១: ជំរើសនានា ក្នុងការគ្រប់គ្រងព្រៃដាំ**

| ការកាត់បន្ថយភាពក្រីក្រ | ការអភិវឌ្ឍន៏សេដ្ឋកិច្ច | ការការពារបរិស្ថាន |
|---|---|---|
| សហគមន៏ព្រៃឈើ<br>ការដាំឈើដោយសហគមន៏ ដើម្បីធ្វើអុស<br>ការដាំឈើដោយសហគមន៏នៅលើដីសាធារណៈ<br>ការគ្រប់គ្រងព្រៃឈើដោយ មានការចូលរួម<br>កសិ-រុក្ខកម្ម<br>ការដាំឈើលំអទីក្រុង | ការដាំឈើដោយក្រុមហ៊ុន<br>ក្រុមហ៊ុនឯកជន/អ្នកម៉ៅការតូចតាច<br><br>ការដាំឈើនៅលើដីចំការឯកជន | ការគ្រប់គ្រងដោយរដ្ឋាភិបាល<br>ការគ្រប់គ្រងតំបន់ការពារដោយមានកិច្ចសហការ |

៦.១.៣ កំណត់តំបន់អាទិភាពសំរាប់ការងារការដាំឈើ។ បណ្តាផែនទីនានានៅក្នុងឧបសម្ព័ន្ធទី៥ បង្ហាញៈ

o គំរបព្រៃ

o ចំណាត់ថ្នាក់ទីជំរាល

o គុណភាពដី

o កំរិតនៃការរុករានទន្ទ្រាន

o ភាពក្រីក្រ

ដែលក្រោយពេលសិក្សាដោយប្រៀបធៀបជាមួយនឹងលក្ខណៈវិនិច្ឆ័យ និងសន្ទស្សន៍នានានៅក្នុងឧបសម្ព័ន្ធទី២គេនឹងទទួលបាននូវទីតាំងមួយចំនួនដែលមានសក្តានុពលសំរាប់ការងារដាំដើមឈើ ។ សន្ទស្សន៍នានាដែលសមស្រប សំរាប់បំពេញកម្មវត្ថុនៃការដាំដើមឈើ មានបង្ហាញក្នុងតារាងទី ២ ខាងក្រោមៈ

**តារាងទី២: លក្ខខណ្ឌសមស្របសំរាប់បំពេញកម្មវត្ថុនៃការដាំឈើ**

| | **ការកាត់បន្ថយភាពក្រីក្រ** | **ការការពារបរិស្ថាន** | **ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ** |
|---|---|---|---|
| ជំរាល | ព្របស្មើ-ជំរាលមធ្យម | ជំរាលខ្លាំង | ព្របស្មើ |
| កំរិតជីជាតិដី | មធ្យម-ខ្ពស់ | មួយណាក៏បាន | មធ្យម-ខ្ពស់ |
| កំរិតនៃការរុករានទន្ទ្រាន | ខ្ពស់-មធ្យម | មធ្យម-ខ្ពស់ | សំរាប់តំបន់ដែលពុំមានព្រៃ |
| កំរិតនៃភាពក្រខ្សត់ | ខ្ពស់-មធ្យម | ទាប-មធ្យម | ទាប |

៦.១.៤ កត់ត្រាទុកនូវរាល់ពតិមានដែលប្រមូលបាននៅក្នុង*សំណុំឯកសារកត់ត្រាអំពីទីតាំង*។ការកត់ត្រានេះនឹងត្រូវកែលំអជាបន្តបន្ទាប់គ្រប់ដំណើរការនៃការកំណត់ទីតាំង ដើម្បីដាក់បញ្ចូលនូវៈ

o កម្មវត្ថុនៃការដាំដើមឈើ

o ទីតាំង

o ទំហំដី

o ជំរើសក្នុងការគ្រប់គ្រង

o ស្ថានភាពនៃផែនការប្រើប្រាស់ដី

o បញ្ជីរផ្ទៀងផ្ទាត់ពតិមាន លទ្ធផលនៃការវាយតំលៃជាជំហានតំបូង និងចំណាត់ថ្នាក់ជាអាទិភាព

o លទ្ធផលនៃការសិក្សាអំពីលទ្ធភាពដែលអាចធ្វើបាន ( ការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ការវិភាគសេដ្ឋកិច្ចលើចំណាយនិងចំណូល)

៦.១.៥ ប្រសិនបើទីតាំងនោះសមស្របនឹងលក្ខខណ្ឌដែលមាននៅក្នុងតារាងទីពីរខាងលើ នោះត្រូវបញ្ជូនសំណុំឯកសារដែលកត់ត្រាអំពីទីតាំងទៅឱ្យអ្នកដែលត្រូវអនុវត្តការងារដាំដើមឈើដើម្បីបន្តដំណើរទៅជំហានទី២ជាបន្តទៀត បើមិនដូច្នោះទេត្រូវបញ្ចប់ដំណើរការនេះនៅត្រឹមក៏រិតនេះ ។

## ៦.២ ជំហានទី២_ការសិក្សាស្វែងយល់អំពីការកាន់កាប់ដី/ សុវត្ថិភាពនៃការប្រើប្រាស់ធនធាន

**គោលដៅ:** កំណត់ថ្នាក់នៃការកាន់កាប់ដី/សុវត្ថិភាពនៃការប្រើប្រាស់ធនធានដែលជាតំរូវការជាបឋមសំរាប់ការជ្រើសរើសទីតាំងសំរាប់ដាំដើមឈើ ។

៦.២.១ តើការកាន់កាប់ដី/សុវត្ថិភាពនៃការប្រើប្រាស់ធនធានត្រូវបានធានានៅក្នុងទីតាំងដែលបានកំណត់? ដំណើរការនេះអាចអនុវត្តបានតែនៅក្នុងទីតាំងណាដែលសុវត្ថិភាពរយៈពេលវែងនៃការកាន់កាប់ដី/ការប្រើប្រាស់ធនធានត្រូវបានធានា ។ ការពិចារណាជាអាទិភាពគួរផ្តល់ចំពោះទីតាំងទាំងឡាយណាដែលផែនការនៃការប្រើប្រាស់ដីកំពុងដំណើរការ ។

៦.២.២ ប្រសិនបើការកាន់កាប់ដី/សុវត្ថិភាពនៃការប្រើប្រាស់ធនធានមិនត្រូវបានធានា គេគួរចាប់ផ្តើមដំណើរការធ្វើផែនការនៃការប្រើប្រាស់ដី ។ ការជ្រើសរើសទីតាំងដែលត្រូវដាំដើមឈើនឹងត្រូវផ្អាកមួយរយៈដោយរង់ចាំលទ្ធផល នៃការធ្វើផែនការប្រើប្រាស់ដី ។

៦.២.៣ ប្រសិនបើការកាន់កាប់ដី/សុវត្ថិភាពនៃការប្រើប្រាស់ធនធានត្រូវបានធានា ផែនការនៃការប្រើប្រាស់ដីកំពុងដំណើរការ ឬក៏មានផែនការនឹងដំណើរការ នោះគេត្រូវបន្តទៅជំហានទី៣ ជាបន្តទៀត ។

## ៦.៣ ជំហានទី៣_ការសិក្សាស្វែងយល់ដោយត្រួសៗអំពីលក្ខខណ្ឌនៃទីតាំង (លទ្ធភាពដែលអាចធ្វើបាន)

**គោលដៅ:** ការសិក្សាស្វែងយល់អំពីភាពសមស្របនៃទីតាំងដោយផ្អែកលើពត៌មានដែលមាននិងការចុះសិក្សាដោយត្រួសៗនៅនឹងទីកន្លែង ។

បញ្ហាសំខាន់ៗត្រូវដោះស្រាយឱ្យចប់សព្វគ្រប់នៅក្នុងដំណាក់កាលនេះ ។ តាមធម្មតាគេអាចអនុវត្តបានឆាប់រហ័ស និងមិនសូវចំណាយសោហ៊ុយខ្ពស់ពេកទេ ហើយអាចជំរុះចោលនូវទីតាំងដែលមិនសមស្រប ។

៦.៣.១ បំពេញបញ្ជីរសំណួរផ្ទៀងផ្ទាត់គំរូ ដូចដែលមានបង្ហាញក្នុងឧបសម្ព័ន្ធទី ៤។ ពតិមានគួរដកស្រង់ពីប្រភព ដែលមានស្រាប់ ដូចជា:

- ទិន្ន័យជំរឿនរបស់ភូមិ
- ផែនការអភិវឌ្ឍន៏ឃុំ
- ផែនទីប្រើប្រាស់ដី
- ផែនទីភ័យន្តរាយ
- ទិន្ន័យ PLUP
- តំបន់អេកូឡូស៊ីកសិកម្ម
- ទិន្ន័យរបស់ SEILA

៦.៣.២ ចុះពិនិត្យទីកន្លែងដោយត្រួសៗ។ មានហេតុផលពីរយ៉ាងក្នុងការធ្វើការងារនេះ:

- ប្រមូលពតិមានដែលមិនទាន់អាចរកបានពីប្រភពដែលមានស្រាប់ដើម្បីបំពេញបញ្ជីរសំណួរផ្ទៀងផ្ទាត់
- ផ្ទៀងផ្ទាត់ពតិមានដែលទទួលបានពីប្រភពទីពីរជាមួយនឹងអ្វីដែលមានស្រាប់នៅនឹងទីកន្លែង ជាពិសេស ស្ថានភាពទាក់ទងនឹងការប្រើប្រាស់ដី និងអ្នកប្រើប្រាស់ដីនាពេលបច្ចុប្បន្ន និង ការប្រើប្រាស់ដីនាពេល អនាគត ដើម្បីមានលទ្ធភាពដោះស្រាយជំលោះដែលអាចកើតមានឡើង។

៦.៣.៣ សិក្សាវាយតម្លៃនូវពតិមានដែលទទួលបានដើម្បីពិនិត្យទីតាំងដែលមានសក្តានុពលសំរាប់ដាំដើមឈើ។ ទិន្ន័យ អំពីសេដ្ឋកិច្ច-សង្គមដែលទទួលបានគឺជាទិន្ន័យគុណភាពមិនមែនជាបរិមាណទេ ជាហេតុធ្វើឱ្យគេមិនអាច វាស់វែង ឬ ធ្វើចំណាត់ថ្នាក់បាន ដូច្នេះទាមទារឱ្យមានការគិតពិចារណាឱ្យបានសមហេតុផលដើម្បីធ្វើសេចក្តី សំរេចចិត្ត។

៦.៣.៤ កែសំរួល*សំណុំឯកសារកត់ត្រាអំពីទីតាំង*

៦.៣.៥ បន្តទៅជំហានទី៤

## ៦.៤ ជំហានទី៤_ការធ្វើចំណាត់ថ្នាក់តំបន់ដែលត្រូវដាំឈើ

**គោលដៅ:** ដើម្បីធ្វើចំណាត់ថ្នាក់អាទិភាពសំរាប់តំបន់

៦.៤.១ សិក្សាវាយតម្លៃឡើងវិញនូវទីតាំងតាមពត៌មានដែលប្រមូលបានពីទីវាលជាក់ស្តែង និង សិក្សាវាយតម្លៃអំពីលក្ខខណ្ឌសេដ្ឋកិច្ច-សង្គម ទៅតាមចំណាត់ថ្នាក់អាទិភាពនៅក្នុងតារាទី៣ ។

**តារាទី៣: ចំណាត់ថ្នាក់ជាអាទិភាព**

| | **ការកាត់បន្ថយភាពក្រីក្រ** | **ការការពារបរិស្ថាន** | **ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ** |
|---|---|---|---|
| លក្ខខណ្ឌនៃទីតាំង | ដូចក្នុងតារាងទី២ | ដូចក្នុងតារាងទី២ | ដូចក្នុងតារាងទី២ |
| កំរិតនៃការខូចខាតប្រភពធនធាន | ខ្ពស់ | មធ្យម-ខ្ពស់ | សំរាប់តំបន់ដែលគ្មានព្រៃ |
| កំរិតនៃភាពក្រីក្រ | ខ្ពស់ | មធ្យម-ខ្ពស់ | ទាប |
| លក្ខខណ្ឌសេដ្ឋកិច្ច-សង្គម | ល្អប្រសើរ | ល្អប្រសើរ | ល្អប្រសើរ |

៦.៤.២ កែសំរួល*សំណុំឯកសារកត់ត្រាអំពីទីតាំង*

៦.៤.៣ ប្រសិនបើទីតាំងនោះចូលក្នុងចំណាត់ថ្នាក់អាទិភាព (សំរាប់បំពេញកម្មវត្ថុនៃការដាំឈើណាមួយ) ត្រូវបន្តទៅជំហានទី៥ ទៀត ។

៦.៤.៤ ប្រសិនបើទីតាំងនោះមិនចូលក្នុងចំណាត់ថ្នាក់អាទិភាពទេគេត្រូវកត់ត្រាទុកនៅក្នុងទីតាំងដែលសមស្របសំរាប់ការសិក្សាវាយតម្លៃនាពេលអនាគត នៅក្នុងកំរិតអាទិភាពទាបជាង ហើយដំណើរការត្រូវចប់នៅត្រឹមនេះ ។

## ៦.៥ ជំហានទី៥_ការសិក្សាវាយតម្លៃលំអិត (សិក្សាអំពីលទ្ធភាពដែលអាចធ្វើបាន)

**គោលដៅ:** ធ្វើការសិក្សាលំអិតដើម្បីស្វែងយល់អំពីលទ្ធភាពសេដ្ឋកិច្ច និង ដើម្បីកាត់បន្ថយផលប៉ះពាល់សង្គម និងបរិស្ថាន ។

ដើម្បីអាចធ្វើសេចក្តីសន្និដ្ឋានបាន មកដល់ចំណុចនេះទាមទារឱ្យមានការចុះសិក្សាជាក់ស្តែងនៅក្នុងទីវាល ការវិភាគដោយល្អិតល្អន់ និង ការជួបសម្ភាសន៍ជាមួយប្រជាជនមូលដ្ឋាន ។ នេះគឺជាដំណើរការមួយដែលទាមទារនូវពេលវេលានិងចំណាយច្រើនបំផុត ប៉ុន្តែគេមិនត្រូវមើលរំលងដំណើការនេះទេ ព្រោះវាជាកត្តាកំណត់ជោគជ័យក្នុងការងារដាំដើមឈើ ។

៦.៥.១ សិក្សាអំពីលទ្ធភាពដែលអាចធ្វើបាន យកល្អត្រូវប្រមើលមើលក្នុងបរិបទនៃដំណើរការធ្វើផែនការប្រើប្រាស់ដី

ដើម្បីទទួលបាននូវការយល់ដឹងបន្ថែមទៀតនូវលក្ខខណ្ឌនយោបាយ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ព្រមទាំងផលប៉ះពាល់ (ជាវិជ្ជមាន និង អវិជ្ជមាន) ពីការដាំឈើទៅលើស្ថានភាពបច្ចុប្បន្ន។

ការផ្តល់កម្មសិទ្ធិដីធ្លីត្រូវពិចារណាអំពីផលប្រយោជន៍ សិទ្ធិតាមផ្លូវច្បាប់និងផែនការរយៈពេលវែងរបស់វិស័យពាក់ព័ន្ធផ្សេងៗទៀតដែលជាប់ទាក់ទង ឬក៏ប៉ះពាល់ដោយផែនការដាំដើមឈើ។ ការងារនេះត្រូវធ្វើឡើងដោយមានកិច្ចពិគ្រោះយោបល់ជាមួយនឹងសហគមន៍ដែលទទួលផលប៉ះពាល់ ដោយធ្វើការពិចារណាអំពីការទាមទារស្របច្បាប់របស់ពួកគេ ហើយត្រូវគិតគូរផងដែរអំពីតម្រូវការប្រើប្រាស់ដីសំរាប់វិស័យកសិកម្ម និងចិញ្ចឹមសត្វនាពេលបច្ចុប្បន្ននិងពេលអនាគត សិទ្ធិប្រើប្រាស់ផលព្រៃឈើជាលក្ខណៈប្រពៃណី និង តម្រូវការខាងការអភិរក្ស។

នៅក្នុងជំហាននេះមានរួមបញ្ចូលនូវការសិក្សាអំពីហេតុប៉ះពាល់ដល់សង្គម និងបរិស្ថាន ដែលក្នុងនោះត្រូវចាប់អារម្មណ៍លើ:

- ចំនួនប្រជាជន និងសហគមន៍មូលដ្ឋានដែលទទួលផលប៉ះពាល់ដោយចំការឈើដាំ
- ដោយមធ្យោបាយអ្វីដែលប្រជាជន និងសហគមន៍មូលដ្ឋានទទួលផលប៉ះពាល់ពីចំការឈើដាំ
- ចំនួនទីតាំងដែលត្រូវដកចេញពីផែនការដាំដើមឈើដើម្បីទុកឱ្យសហគមន៍ប្រើប្រាស់
- ភាពដែលអាចរកបាន នៃដីសំរាប់ដាំដើមឈើ និង ទំហំដែលសមស្រប
- ផលប៉ះពាល់បរិស្ថានដល់ធនធានទឹក ភ្លៀង ដី និង ជីវចម្រុះជាតិ
- ជំរើសក្នុងការកាត់បន្ថយជំលោះ និង ផលប៉ះពាល់ជាអវិជ្ជមាន

ឯកសារយោងនានាមានដូចខាងក្រោម:


- IUCN/WWF, 2000, Planning Forest Plantations
- ITTO, 1993, ITTO guidelines for the Establishment and Sustainable Management of Planted Tropical Forests
- ITTO, 2002, Guidelines for the Restoration, Management and Rehabilitation of Degraded and Secondary Tropical Forests
- ក្រសួងបរិស្ថាន. មិនមានឆ្នាំ. គោលការណ៍ណែនាំសំរាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- នាយកដ្ឋានរុក្ខា-ប្រមាញ់, 2000. គោលការណ៍ណែនាំសំរាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (Guidelines for Sustainable Forest Management)

៦.៥.២ ត្រូវគិតគូរផងដែរថាអ្វីអាចនឹងកើតមានឡើងប្រសិនបើគ្មានគំរោងដាំឈើទេ ហើយក្នុងករណីនោះតើមូលហេតុនៃការធ្វើឱ្យព្រៃរេចរិលត្រូវបានលប់បំបាត់ឬទេប្រសិនបើមិនដូច្នោះទេឱកាសនៃការទទួលជោគជ័យមានតិចតួចណាស់ ។

៦.៥.៣ ត្រូវធ្វើការវិភាគសេដ្ឋកិច្ចលំអិត ដោយគិតគូរនូវចំណាយ-ចំណូល ដោយរាប់បញ្ចូលទាំងជីវចំរុះ មុខងារនៃសេវាកម្មខាងបរិស្ថាន ផលប្រយោជន៍សង្គម និង សក្តានុពលនៃការបង្កើតផលព្រៃឈើថ្មីៗ។ ជារួមការវិភាគនេះត្រូវចែកចេញជាពីរផ្នែកគឺ:

- o ចំណាយ-ចំណូលសំរាប់សកម្មភាពដែលស្នើសុំ និង ចំណាយ-ចំណូល នៃការប្រើប្រាស់ដីសំរាប់គោលបំណងផ្សេងៗទៀត
- o ការបែងចែកនូវចំណាយ និង ចំណូល ដល់ភាគីពាក់ព័ន្ធ

៦.៥.៤ កែសំរួល*សំណុំឯកសារកត់ត្រាអំពីទីតាំង*

៦.៥.៥ ប្រសិនបើលទ្ធផលនៃការសិក្សាវាយតម្លៃលំអិតវិជ្ជមាន នោះត្រូវបន្តទៅជំហានទី ៦

៦.៥.៦ ប្រសិនបើលទ្ធផលនៃការសិក្សាវាយតម្លៃលំអិតបែរជាអវិជ្ជមាន នោះគេត្រូវបោះបង់ទីតាំងនោះចោលហើយបញ្ឈប់ដំណើរការនេះត្រឹមទីនេះ ។

## ៦.៦ ជំហានទី៦_ការស្វែងរកថវិកា និង ការអនុវត្ត

**គោលដៅ:** ធានានូវប្រភពថវិកាគ្រប់គ្រាន់សំរាប់ការអនុវត្តការងារដាំដើមឈើ ។

៦.៦.១ ប្រសិនបើអាចរកថវិកាបានពីរដ្ឋបាលព្រៃឈើ នោះការងារដាំដើមឈើអាចចាប់ផ្តើមអនុវត្ត បានភ្លាម ដោយផ្អែកលើគោលការណ៍ណែនាំផ្នែកទីពីរ

៦.៦.១ ប្រសិនបើអាចរកថវិកាមិនទាន់មាននោះគេត្រូវរៀបចំគំរោងសំណើទៅកាន់បណ្តាអ្នកផ្តល់ជំនួយនានា អ្នកវិនិយោគនិងរដ្ឋាភិបាល ។